MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# សន្ទរកថាបើក ថ្លែងទៅកាន់វេទិកានយោបាយកម្រិតខ្ពស់ នៃសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស

លោកប្រធាន ជាទីគោរព
ប្រតិភូកិត្តិយសទាំងឡាយ ជាទីរាប់អាន

ថ្ងៃនេះ ខ្ញុំមានកិត្តិយសសូមថ្លែងសន្ទរកថាទៅកាន់វេទិកានយោបាយកម្រិតខ្ពស់ នៃសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សជាលើកដំបូង។

នៅពេលខ្ញុំបានថ្លែងសន្ទរកថាចុងក្រោយទៅកាន់ក្រុមប្រឹក្សានេះ ខ្ញុំបាននិយាយយ៉ាងវែងអំពីភាពឃោរឃៅ និងទង្វើខ្លះសីលធម៌របស់ពួកជ្រុលនិយមហិង្សា។ ឱព្រះអើយ សកម្មភាពគួរឲ្យរន្ធត់ដែលពួកគេបានប្រព្រឹត្តនៅតែបន្តមានជារៀងរាល់ថ្ងៃ ហើយយើងសូមថ្កោលទោសចំពោះការប្រព្រឹត្តអំពើឃោរឃៅគ្មានត្រាប្រណី របស់ពួកគេ រៀងរាល់ថ្ងៃ។ អញ្ចឹងទេ ប្រសិនជាយើងមិនមានការប្រុងប្រយ័ត្ន ប្រសិនជាយើងមិនមានគោលការណ៍ច្បាស់លាស់ ហើយមានការឆ្លៀសវៃគ្រប់គ្រាន់ ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើងដើម្បីកាច់ចង្កូមពួកជ្រុលនិយមហិង្សាទេ នោះយើងនឹងផ្តល់ផលប្រយោជន៍ឲ្យពួកគេ ដោយមិនដឹងខ្លួន និងដែលមិនគួរអត់ឱនឡើយ។ តើយើងត្រូវកំណត់ការបើកទំព័រសតវត្សដែលពោរពេញទៅដោយកោលាហលស្រាប់នេះ ដែលអាស្រ័យទាំងស្រុងទៅលើយើងទាំងអស់គ្នា ដោយមិនបណ្តោយខ្លួនឲ្យធ្លាក់ក្នុងស្ថានភាពដូចនោះយ៉ាងដូចម្តេចទៅ។ សម្រាប់យើងទាំងអស់គ្នា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនអាចឲ្យជនណាម្នាក់យកមកប្រើប្រាស់ធ្វើជាការលេងសើច ឬដើម្បីបំភាន់ភ្នែកឡើយ ផ្ទុយទៅវិញច្បាប់ទាំងនោះ ត្រូវតែបានអនុវត្តយ៉ាងពេញលេញ។ អាស្រ័យហេតុនេះ និងដោយមិនបន្ថយការបន្តលុបបំបាត់អំពើភេរវកម្ម ខ្ញុំនឹងផ្តោតសេចក្តីថ្លែងការណ៍នេះលើឥរិយាបទទូទៅរបស់រដ្ឋជាសមាជិកនានា ទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួន ក្នុងការលើកស្ទួយការពារសិទ្ធិមនុស្ស។

គិតមកទល់ពេលនេះគឺមានរយៈពេល ៧០ ឆ្នាំហើយ ចាប់ពីធម្មនុញ្ញដ៏មហាអស្ចារ្យរបស់អង្គការសហប្រជាជាតិ ត្រូវបានតាក់តែងឡើង ហើយចាប់តាំងពីពេលនោះមក រដ្ឋនានាក៏បានសរសេរ និងបានយល់ព្រមអនុវត្តផងដែរ នូវសន្ធិសញ្ញាអន្តរជាតិដ៏រឹងមាំមួយចំនួន ដើម្បីកំណត់ក្នុងច្បាប់ជាធរមាន នូវគោលការណ៍គតិយុត្តស្តីពីសិទ្ធិមនុស្ស។ គោលការណ៍គតិយុត្តទាំងនោះ បានមកពីការស្រង់បទពិសោធន៍របស់មនុស្សទាំងអស់ រាល់ពាក្យសំដីដាស់តឿន និងការស្រែកដង្ហោយហៅនៃប្រវត្តិសាស្ត្ររបស់មនុស្សរួមបញ្ចូលគ្នារបស់យើង។

ថ្ងៃនេះ នៅក្នុងបន្ទប់នេះ មានវត្តមានតំណាងកិត្តិយសនៃរដ្ឋជាច្រើន ដែលរដ្ឋនីមួយៗសុទ្ធតែបានរួមចំណែកដ៏ធំធេង និងដ៏ថ្លៃថ្លា ដើម្បីបុព្វហេតុមនុស្សជាតិ។ តាមរយៈការផ្តល់សច្ចាប័នលើធម្មនុញ្ញអង្គការសហប្រជាជាតិ រដ្ឋទាំងអស់ បានធ្វើការប្តេជ្ញាចិត្តមួយច្បាស់លាស់ ដែលខ្ញុំសូមដកស្រង់សំដីនោះ *"ដោយអះអាងជាថ្មី នូវជំនឿលើសិទ្ធិជាមូលដ្ឋាន ក្នុងសេចក្តីថ្លៃថ្នូរ និងតំលៃមនុស្សជាតិ ក្នុងភាពស្មើគ្នានៃសិទ្ធិរវាងបុរស*

*និងស្ត្រី ព្រមទាំងរវាងប្រទេសធំ និងប្រទេសតូច និងបង្កើតលក្ខខណ្ឌ ដែលអាចរក្សាបាននូវយុត្តិធម៌ និងការគោរពកាតព្វកិច្ចទាំងឡាយ ដែលកើតចេញពីសន្ធិសញ្ញា និងប្រភពដទៃនៃច្បាប់អន្តរជាតិ និងដើម្បីលើកកម្ពស់វឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់កាន់តែល្អប្រសើរ ក្នុងសេរីភាពកាន់តែធំទូលំទូលាយ។"*

ទោះជាមានការប្តេជ្ញាចិត្តបែបនេះក្តី ក៏នៅតែកើតមានជាប្រក្រតីគួរឲ្យភ្ញាក់ផ្អើល នូវការមិនគោរព និងការរំលោភសិទ្ធិមនុស្ស ដែលមានពេលខ្លះ ករណីនេះអាចឈានដល់កម្រិតមួយ គួរឲ្យតក់ស្លុតក៏សឹងមាន។

រដ្ឋមួយចំនួន លើកសំអាងពីករណីពិសេស ឬករណីអញ្ញត្រកម្ម។ រដ្ឋទាំងនោះ ចាប់ច្បិច និងជ្រើសរើសយកការអនុវត្តរវាងសិទ្ធិផ្សេងៗ។ រដ្ឋាភិបាលមួយ អាចនឹងគាំទ្រទាំងស្រុងចំពោះសិទ្ធិមនុស្សរបស់ស្ត្រី និងសិទ្ធិរបស់សហគមន៍មនុស្សស្រីស្រឡាញ់មនុស្សស្រី មនុស្សប្រុសស្រឡាញ់មនុស្សប្រុស មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) ប៉ុន្តែមានការអល់អែកចិត្តនឹងការលើកឡើងណាមួយថាសិទ្ធិទាំងនោះត្រូវអនុវត្តផងដែរ ចំពោះទេសន្តរប្រវេសន៍ដែលមានស្ថានភាពមិនប្រក្រតី។ រដ្ឋមួយទៀត អាចនឹងគោរពយ៉ាងហ្មត់ចត់ចំពោះសិទ្ធិអប់រំ ប៉ុន្តែអាចនឹងជំទាស់ទាំងស្រុង ចំពោះទស្សនៈនយោបាយណាដែលប្រឆាំង។ រដ្ឋទីបីមួយ អាចនឹងរំលោភទូទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃប្រជាពលរដ្ឋរបស់ខ្លួន ទន្ទឹមនឹងនេះ រដ្ឋនេះការពារយ៉ាងខ្លាំងក្លានូវឧត្តមគតិសិទ្ធិមនុស្ស នៅចំពោះមុខប្រទេសជាមិត្តរបស់ខ្លួន។

នៅក្នុងប៉ុន្មានខែចុងក្រោយនេះ ខ្ញុំមានកង្វល់ជាខ្លាំង ដោយការប្រមាថ និងការមិនគោរពពីសំណាក់រដ្ឋមួយចំនួន ចំពោះស្ត្រី និងបុរស ដែលលោកបានតែងតាំងធ្វើជាអ្នកជំនាញការឯករាជ្យរបស់ក្រុមប្រឹក្សានេះ- និងដោយការសងសឹក និងយុទ្ធនាការលាបពណ៌គ្នាផងដែរ ដែលជាញឹកញយបំផុត ត្រូវបានធ្វើឡើងប្រឆាំងនឹងតំណាងសង្គមស៊ីវិល រាប់ទាំងអ្នកទាំងឡាយដែលចូលរួមធ្វើការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស និងស្ថាប័នផ្សេងៗរបស់ខ្លួន។ ខ្ញុំសូមអំពាវនាវជាថ្មីម្តងទៀតដល់អ្នករាល់គ្នា សូមផ្តោតការយកចិត្តទុកដាក់លើកង្វល់ពិតប្រាកដ ជាជាងការវាយប្រហារលើអ្នករិះគន់ - ទោះជាថាបុគ្គលនោះ ត្រូវបានរដ្ឋភាគីប្រគល់អាណត្តិឲ្យ ឬគាត់ជាសមាជិករបស់ការិយាល័យខ្ញុំ ឬជាអ្នកការពារសិទ្ធិមនុស្សមួយរូបក្តី។

លោកប្រធាន ជាទីគោរព

ចំនួនភាគច្រើនលើសលប់នៃជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សនៅជុំវិញពិភពលោក មានស្ថានភាពពីរដូចគ្នា៖ ការដកហូតសិទ្ធិ និងការរើសអើង - ទោះជាដោយសារបញ្ហាពូជសាសន៍ ឬជាតិពន្ធុ ភេទ ជំនឿ ទំនោរផ្លូវភេទ ឋានៈ ឬវណ្ណៈសង្គម ក៏ដោយ។ ពីភាពអត់ឃ្លានរហូតដល់ការសម្លាប់រង្គាល អំពើហិង្សាផ្លូវភេទ និងទាសភាព ការរំលោភសិទ្ធិមនុស្ស បានចាក់ឫសយ៉ាងជ្រៅក្នុងកត្តាលាក់កំបាំងទាំងនេះ ហើយមានពេលខ្លះ មិនជាលាក់កំបាំងណាស់ណាទេ។

កត្តាទាំងនេះ មិនបានកើតឡើងដោយឯកឯងនោះទេ។ ភាគច្រើនបំផុតនៃការរំលោភសិទ្ធិមនុស្ស កើតចេញពីការជ្រើសរើសយកគោលនយោបាយ ដែលកម្រិតកំណត់សេរីភាព និងការចូលរួម ហើយវាបង្កើតឧបសគ្គដល់ការចែករំលែកប្រកបដោយសមធម៌នៃធនធាន និងកាលានុវត្តភាព។

លោកប្រធាន ជាទីគោរព

ឧបករណ៍ដ៏មានឥទ្ធិពលបំផុតនៅក្នុងឃ្លាំងសព្វាវុធ ដែលយើងមាន ដើម្បីប្រឆាំងនឹងភាពក្រីក្រ និងជម្លោះ គឺជាអាវុធនៃការណែនាំដ៏ល្អបំផុត។ ការគោរពសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប យុត្តិធម៌ ការអប់រំ សមភាព - ទាំងនេះ គឺជាសមាសធាតុចាក់ស្រេះដ៏រឹងមាំ ដែលនឹងកសាងសង្គមយុត្តិធម៌ មានការជឿជាក់ និងរឹងមាំ ការអភិវឌ្ឍពិតប្រាកដ និងសន្តិភាពស្ថិតស្ថេរជានិរន្ត។

ការពិភាក្សារបស់យើងក្នុងសម័យប្រជុំនេះ អាចនឹងមានប្រយោជន៍ខ្លះទៅបាន លុះត្រាតែតំណាងរដ្ឋទាំងឡាយ ដែលមានវត្តមាននៅទីនេះ ទទួលយកអនុសាសន៍របស់ក្រុមប្រឹក្សា ការត្រួតពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់របស់ខ្លួន និងយន្តការជំនាញរបស់ខ្លួន នៅក្រៅបន្ទប់នេះ និងផ្តល់ប្រសិទ្ធភាពពិតប្រាកដដល់ចំណុចទាំងឡាយនេះ ត្រង់ចំណុចណាដែលជាបញ្ហា - នៅក្នុងប្រទេសរបស់អ្នករាល់គ្នា។

ក្នុងនាមខ្ញុំផ្ទាល់ ជាអតីតអ្នកការទូតមួយរូប ខ្ញុំដឹងច្បាស់អំពីការព្រួយបារម្ភនឹងពិធីការ ដែលធ្វើឲ្យតំណាងរដ្ឋនានា ខំប្រជ្រៀតរកកន្លែងអង្គុយនៅក្រុមប្រឹក្សា ឬរកចន្លោះពេលនិយាយឲ្យលេចធ្លោជាងគេ នៅក្នុងកិច្ចប្រជុំកំពូលសំខាន់ៗ ដោយសង្ឃឹមថា នឹងទទួលបានការចាប់អារម្មណ៍ខ្លាំង និងការគោរពពីមនុស្សលើពិភពលោកចំពោះប្រទេសជាតិរបស់ខ្លួន។ ប៉ុន្តែការបារម្ភនេះតែមួយគត់ គឺមិនមានន័យអ្វីនោះទេ ពីព្រោះអ្នករាល់គ្នាដឹងថាយ៉ាងម៉េចហើយ នៅពេលដែលមនុស្ស ត្រូវគេបិទសិទ្ធិមិនឲ្យនិយាយស្តី ពេលដែលពួកគេខ្លាចមានការចាប់ខ្លួនដោយបំពាន ឬស្ថិតក្នុងស្ថានភាពអាក្រក់ជាងនេះនោះ។

អ្នករាល់គ្នាក៏ដឹងដែរថាវាយ៉ាងម៉េចហើយ នៅពេលដែលនគរបាលប្រើទារុណកម្ម ហើយនៅពេលដែលការដាក់បង្ហោះលើបណ្តាញព័ត៌មានសង្គម ត្រូវបានបង្ក្រាបយ៉ាងព្រៃផ្សៃនោះ។ អ្នករាល់គ្នាក៏ដឹងដែរថាវាយ៉ាងម៉េចហើយ នៅពេលដែលការរើសអើងសំដៅឲ្យមានភាពក្រីក្រ ខណៈដែលអ្នកមានអំណាច អ្នកមានទ្រព្យសម្បត្តិ ដែលពុករលួយ បាននិងកំពុងស៊ីចាក់ច្រាស់នូវសម្បត្តិសាធារណៈ ដោយមានតុលាការពុករលួយគាំទ្រពីក្រោយនោះ។ អ្នករាល់គ្នាក៏ដឹងដែរថាវាយ៉ាងម៉េចហើយ នៅពេលដែលស្ត្រីត្រូវគេចាត់ទុកដូចជាកម្មសិទ្ធិ និងកុមាររងការអត់ឃ្លាន និងមិនបានចូលរៀន ស្ថិតក្នុងបរិស្ថានដែលក្រខ្វក់នោះ។

ភស្តុតាងមួយចំនួន អាចមានការលាក់កំបាំង។ ប៉ុន្តែនៅក្នុងប្រទេសជាច្រើន ការពិតអំពីការសម្លាប់រង្គាល និងអំពើហិង្សាផ្លូវភេទ ភាពក្រីក្រដែលរងការរិះគន់យ៉ាងខ្លាំង ការប្រគល់ផ្តាច់មុខនូវសេវាគាំពារសុខភាព និងធនធានសំខាន់ៗផ្សេងទៀតទៅឲ្យអ្នកមានទ្រព្យសម្បត្តិ និងមានខ្នងក្រាស់ ការធ្វើទារុណកម្មលើជនជាប់ឃុំដែលគ្មានអំណាច ការបដិសេធសេចក្តីថ្លៃថ្នូររបស់មនុស្ស - រឿងទាំងនេះ អ្នករាល់គ្នាក៏ដឹងដែរថាវាយ៉ាងណានោះ។ ហើយ ឯកឧត្តម លោកជំទាវទាំងឡាយ កត្តាដែលធ្វើឲ្យរដ្ឋមួយមានកេរ្តិ៍ឈ្មោះពិតប្រាកដនោះ គឺវាគួបផ្សំផងដែរទៅនឹងវិធានការជាក់ស្តែង កាលបើវិធានការណាមួយនោះ ធ្វើឡើងសំដៅបង្ការទប់ស្កាត់ការរំលោភបំពាន និងការដោះស្រាយបញ្ហាវិសមភាពសង្គម ហើយត្រូវមើលទៀតថាតើ រដ្ឋនោះទទួលស្គាល់ ឬមិនទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្លួន ទៅវិញទេ។

ការវាស់វែងពិតប្រាកដតែមួយគត់អំពីតម្លៃរបស់រដ្ឋាភិបាលមួយ មិនមែនទៅលើការបង្ហាញមុខមាត់របស់ខ្លួនជាឱឡារិកអំពីការទូតដ៏មហិមាឡើយ។ ប៉ុន្តែ វាគឺជាវិសាលភាពទៅវិញទេ ដែលរដ្ឋនោះឆ្លើយតបបានឆាប់រហ័សកម្រិតប៉ុនណាចំពោះសេចក្តីត្រូវការ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋខ្លួន និងមនុស្សដទៃទៀត ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឬដែលរដ្ឋាភិបាលនោះត្រួតត្រាជារូបវន្តលើពួកគេ។

អ្នកធ្វើគោលនយោបាយមួយចំនួន យល់ឃើញថា ករណីរបស់ខ្លួនមានលក្ខណៈពិសេស ឬជាករណី

អញ្ញត្រកម្ម ដោយការបង្កើតតថភាពមួយថ្មីទាំងស្រុង ដែលច្បាប់មានចន្លោះប្រហោង ឬមិនមានចែង។ ភាពសមហេតុផលនេះមានច្រើនក្រៃលែងនៅជុំវិញពិភពលោកនាពេលបច្ចុប្បន្ននេះ៖ *ខ្ញុំចាប់ខ្លួនតាមអំពើចិត្ត និងធ្វើទារុណកម្ម ដោយសារតែ សង្គ្រាមបែបថ្មីមួយ តម្រូវឲ្យមានការចាប់ខ្លួន និងធ្វើទារុណកម្ម។ ខ្ញុំឈ្លបយកការណ៍ពីប្រជាពលរដ្ឋរបស់ខ្ញុំ ពីព្រោះការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម តម្រូវឲ្យធ្វើដូច្នេះ។ ខ្ញុំមិនចង់បានជនអន្តោប្រវេសន៍ថ្មី ឬខ្ញុំរើសអើងប្រឆាំងនឹងជនភាគតិច ពីព្រោះអត្តសញ្ញាណសហគមន៍របស់យើង កំពុងត្រូវបានគេគំរាមកំហែងនៅពេលនេះ ដែលករណីនេះ មិនធ្លាប់មានទេពីមុនមក។ ខ្ញុំសំលាប់ដោយមិនចាំបាច់ត្រូវអនុវត្តតាមរូបភាពណាមួយនៃនីតិវិធីត្រឹមត្រូវឡើយ ពីព្រោះប្រសិនជាខ្ញុំមិនធ្វើដូច្នេះទេ អ្នកផ្សេងនឹងសម្លាប់ខ្ញុំ។* ដូច្នេះហើយ ការអនុវត្តបែបនេះ ចេះតែមានជាហូរហែរអញ្ចឹងទៅ នៅពេលដែលយើងកំពុងធ្លាក់ក្នុងវិបត្តិធ្ងន់ធ្ងរ។

ខ្ញុំត្រូវតែរំលឹកអ្នកអំពីសុពលភាពឋិតថេរ និងជាសកលនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋរបស់អ្នក បានសរសេរ និងបានផ្តល់សច្ចាប័ន។ តាមពិតទៅ ទាំងអំពើភេរវកម្ម ទាំងជាសកលភាវូបនីយកម្ម ទាំងទេសន្តរប្រវេសន៍ មិនមែនជាការគំរាមកំហែងបែបថ្មី ដែលអាចលើកយកមកសំអាង ឬធ្វើជាយុត្តិកម្ម ពីការងាកចេញពីមូលដ្ឋានច្បាប់នៃជីវិតនៅលើភពផែនដីឡើយ។ ទាំងនេះមិនមែនជារឿងថ្មីទេ។

ខ្ញុំជឿថាការងាររួមគ្នារបស់យើងនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ពិតជាសំខាន់ខ្លាំងណាស់។ ហើយខ្ញុំសូមស្នើដល់អ្នកទាំងអស់ និងរដ្ឋទាំងឡាយ ដែលអ្នកតំណាងឲ្យ សូមធ្វើការសម្របសកម្មភាពរបស់អ្នក ជាមួយនឹងអនុសាសន៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការរបស់ក្រុមប្រឹក្សានេះ - ដើម្បីទទួលអនុវត្តការងារពិតប្រាកដនេះពីសភាដ៏ឧត្តុងឧត្តមនេះ និងនាំយកវាទៅតាមដងផ្លូវ និងគ្រួសារទាំងឡាយនៃប្រទេសរបស់អ្នក។

លោកប្រធាន ជាទីគោរព

ខ្ញុំដឹងច្បាស់ពីសេចក្តីត្រូវការ និងទំនួលខុសត្រូវកំពុងតែកើនឡើង ដែលការិយាល័យរបស់ខ្ញុំត្រូវទទួលបន្ទុកបន្ថែមនេះ និងសេចក្តីត្រូវការ ដើម្បីធានាថា យើងអាចបម្រើប្រជាជននៃពិភពលោកឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត - ជាពិសេសបំផុតនោះគឺជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស។

នៅថ្ងៃព្រហស្បតិ៍ ខ្ញុំនឹងបង្ហាញពីការរៀបចំអង្គការលេខសំខាន់ៗឡើងវិញ របស់ការិយាល័យខ្ញុំ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យឡើងវិញទូទៅលើមុខងារ។ វានឹងមានការរុះរើមួយចំនួននៅទីស្នាក់ការកណ្តាល ប៉ុន្តែគោលដៅសំខាន់នោះគឺដើម្បីបង្កើនវត្តមានរបស់យើងនៅតាមការិយាល័យប្រចាំតំបន់ និងប្រទេស ដើម្បីជួយដល់អ្នករាល់គ្នា រដ្ឋជាសមាជិកនានា ដោយផ្ទាល់ថែមទៀត និងដើម្បីធ្វើឲ្យការងាររបស់យើងក្នុងនាមលោកអ្នក មានប្រសិទ្ធភាពតាមដែលអាចធ្វើបាន។

នៅទីបញ្ចប់ ខ្ញុំសូមសម្តែងការដឹងគុណដល់បុគ្គលិកការិយាល័យ OHCHR ទាំងអស់ ជាពិសេសបុគ្គលិកទាំងឡាយដែលធ្វើការក្នុងស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជារៀងរាល់ថ្ងៃ។ ជារឿយៗ ស្ត្រី និងបុរសទាំងនេះ ប្រឈមនឹងសេចក្តីស្លាប់ ដើម្បីលើកស្ទួយការពារគោលការណ៍របស់យើង និងដើម្បីផ្តល់ឲ្យយើងនូវព័ត៌មានសំខាន់ៗ។ ខ្ញុំស្រងាកចិត្តពេលដែលបានដឹងថា ដោយសារតែរដ្ឋជាសមាជិកនានាខ្វះឆន្ទៈ ទើបបានជាអង្គការសហប្រជាជាតិ មិនមានតួនាទី ដើម្បីធ្វើការផ្តល់ការគាំទ្រឲ្យបានគ្រប់គ្រាន់ដល់បុគ្គលិក ដែលត្រូវបានរងរបួសនៅក្នុងបេសកកម្មដែលមានហានិភ័យខ្ពស់ ឬដល់ក្រុមគ្រួសាររបស់បុគ្គលិក ដែលត្រូវបានគេ

សម្លាប់នៅក្នុងករណីដូច្នេះ។ និយាយតាមត្រង់ទៅ នេះជាការរន្ធត់ចិត្ត ហើយខ្ញុំអំពាវនាវដល់អ្នកទាំងអស់គ្នា ឲ្យផ្លាស់ប្តូរស្ថានភាពនេះ។

លោកប្រធាន ជាទីគោរព

នៅក្នុងកាលៈទេសៈនៃកង្វល់ពិភពលោកមានការកើនឡើង ខ្ញុំជឿថាមនុស្សលើពិភពលោក បាននិងកំពុងស្រែកអំពាវនាវចង់បានភាពជាអ្នកដឹកនាំដែលមានគំនិតជ្រាលជ្រៅ និងមានការបំផុសគំនិត ស្មើទៅនឹងបញ្ហាទាំងឡាយដែលយើងបាន និងកំពុងប្រឈម។ ដូច្នេះ យើងត្រូវតែបន្តជាថ្មី តាមរយៈចំណាត់ការខ្លាំងក្លាបំផុត ការលះបង់របស់យើងដើម្បីឲ្យសិទ្ធិមនុស្សជាសកល និងសិទ្ធិមិនអាចលក់ដូរ ឬផ្ទេរបាន ក្លាយជាការពិត ដើម្បីបញ្ចប់ការរើសអើង ការដកហូត និងការព្រមិនចេះចប់ មិនចេះហើយ អំពីជម្លោះ និងវិបត្តិដែលទំនងជាបង្កើតឲ្យមានការឈឺចាប់ខ្លាំង និងមិនគួរឲ្យកើតមាន។

តើមានអ្វីនឹងកើតមានសម្រាប់យើងទាំងអស់គ្នា ប្រសិនជាយើងមិនអើពើក្នុងការអនុវត្តសន្ធិសញ្ញា និងគោលការណ៍ទាំងឡាយរបស់យើង? តើអាចជាការខ្វះសតិសម្បជញ្ញៈពេកដែរឬទេ ប្រសិនជាយើងធ្វើឲ្យកើតមានជាថ្មីនូវទិដ្ឋភាពពីសតវត្សទីម្ភៃ ដែលបានធ្វើឲ្យបាត់បង់ក្តីសង្ឃឹម និងជំនឿ ដោយអំពើអមនុស្សធម៌ដ៏អាក្រក់បែបនោះ? អ្នកមិនត្រូវធ្វើឲ្យវាទៅជាដូច្នោះទេ។ នេះគឺជាបន្ទុកមួយដ៏សំខាន់របស់អ្នក និងរបស់យើងទាំងអស់គ្នា។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នានេះ ប្រសិនជាយើងសម្រេចជោគជ័យក្នុងការធ្វើឲ្យល្អប្រសើរឡើង ក្នុងការពង្រឹងស្ថានភាពពិភពលោករបស់យើង នោះ យើងអាចនិយាយបានថា ការស្រែកដង្ហោយហៅរបស់ប្រវត្តិសាស្រ្ត និងការអំពាវនាវរបស់ជនរងគ្រោះរាប់លាននាក់ នៅទីបំផុតនឹងត្រូវបានគេស្តាប់ និងយកចិត្តទុកដាក់ដោះស្រាយ។ ចូរយើងទាំងអស់គ្នាធ្វើឲ្យបាន។

សូមអរគុណ

ចប់

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមមេត្តាទាក់ទងមកៈ រ៉ូភើត ខូលវីល (Rupert Colvile) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧៦៧ / rcolville@ohchr.org) ឬ រ៉ាវីណា ស៊ើមដាសានី (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៦៩/ rshamdasani@ohchr.org) ឬ សេសីល ពូអ៊ីលលី (Cécile Pouilly តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣១០ / cpouilly@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធ៊ី៖** http://twitter.com/UNrightswire

ហ្គោហ្គីល៖ Google+ gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR
បរិយាយសាច់រឿង៖ http://storify.com/UNrightswire